# សុន្ទរកថា

## លោកស្រី ឥម សុគន្ធារី តំណាងសង្គមស៊ីវិលដែលកំពុងអនុវត្តកម្មវិធីប្រយុទ្ធ ប្រឆាំងនឹងមេរោគអេដស៍និងជំងឺអេដស៍

## ថ្លែងក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍

១ ធ ២០១១

សូមគោរពលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ឥស្សរៈជនឆ្នើមថ្នាក់ជាតិនៃផែនការសកម្មភាពរួមអគ្គលេខាធិការអង្គការសហប្រជាជាតិដើម្បីសុខភាពស្ត្រីនិងកុមារ និងឥស្សរៈជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំប្រចាំតំបន់អាស៊ី ប៉ាស៊ីហ្វិក ស្តីពីមេរោគអេដស៍/ជំងឺអេដស៍នៅកម្ពុជា ដែលជាតំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

សូមគោរពឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

សូមគោរពឯកឧត្តមវេជ្ជបណ្ឌិត **នុត សុខុម** ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

សូមគោរពឯកឧត្តម លោកជំទាវ លោក លោកស្រីតំណាងទូត ដៃគូអភិវឌ្ឍន៍ និងតំណាងអង្គការជាតិនិងអន្តរជាតិជាទីគោរព។

បងប្អូនអ្នកផ្ទុកមេរោគអេដស៍ ដែលមានវត្តមាននៅទីនេះជាទីស្រលាញ់រាប់អាន!

ក្នុងនាមសង្គមស៊ីវិល ដែលកំពុងអនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សក្រៃលែងដែលបានចូលរួមជាកិត្តិយសក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍និងជាតិលើកទី១៩ ក្រោមប្រធានបទ"**ឈានឆ្ពោះទៅរក គ្មានការឆ្លងថ្មី គ្មានការរើសអើង គ្មានការស្លាប់** " ។ឆ្លៀតនៅក្នុងឱកាសនេះយើងខ្ញុំសូមសម្តែងនូវមោទនៈភាពដល់គ្រប់ស្ថាប័ណទាំងអស់ជាពិសេសដល់រាជរដ្ឋាភិបាលកម្ពុជាដែលបង្ករអោយមានការចូលរួមជាពហុវិស័យពីគ្រប់ស្ថាប័ណទាំងអស់ជាពិសេសដល់សង្គមស៊ីវិលឱ្យបានរួមចំណែក ក្នុងកិច្ចការងារនេះជាមួយរដ្ឋាភិបាល រហូតទទួលបានជោគជ័យជាបន្តបន្ទាប់ និងទទួលស្គាល់ជាលក្ខណៈជាតិនិងអន្តរជាតិ នូវអត្រានៃការផ្ទុកមេរោគអេដស៍ចុះមកត្រឹម០.៨%នៅឆ្នាំ២០១០។យើងសូមអបអរសាទរដល់ជោគជ័យដែលជាមោទនៈភាពជាតិ!

ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីគោរព!

នាពេលបច្ចុប្បន្ននេះប្រទេសកម្ពុជាក៏ដូចជាប្រទេសនានានៅក្នុងតំបន់ក៏ដូចជានៅទូទាំងពិភពលោកបាននឹងកំពុងសហការណ៍រួមគ្នាក្នុងការសំរេចអោយបាននូវគោលដៅរួមមួយគឺការឈានទៅរកភាពសូន្យគឺគ្មានការឆ្លងថ្មី គ្មានការរើសអើងនិងគ្មានការស្លាប់ពាក់ព័ន្ធទៅនឹងជំងឺអេដស៍។នៅពេលដែលបានលឺនិងឃើញនូវគោលដៅរួមនេះយើងមានការអប់អរណាស់ដោយរំពឹងថានឹងនៅឆ្នាំ២០១៥យើងនឹងឃើញនូវលទ្ធផលទាំងនោះប៉ុន្តែយើងនៅមានការបារម្មណ៍ថាតើយើងត្រូវធ្វើដូចម្តេចដើម្បីសំរេចបាននូវគោលដៅទាំងនោះ។

ដើម្បីចូលរួមចំនែកក្នុងការសំរេចអោយបាននូវជោគជ័យនូវគោលដៅដែលបានគ្រោងទុកតាងនាមអោយសង្គមសីវិលយើងសូមលើកយកនូវចំនុចមួយចំនួនមានដូចខាងក្រោមៈ

**កម្មវិធីបង្ការ** អត្រាគ្របដណ្តប់នៃបទអន្តរាគមន៍ចំពោះក្រុមប្រឈមមុខខ្ពស់ដូចជាក្រុមបុរសស្រលាញ់បុរស អ្នកបំរើសេវាកំសាន្ត ក្រុមអ្នកប្រើបំពានគ្រឿងញៀន នៅមានកម្រិតទាបនៅឡើយ និងស្ត្រីដែលមានផ្ទៃពោះដែលមិនបានទៅទទួលសេវាកាត់បន្ថយការឆ្លងមេរោគអេដស៍ទៅកូនក៏នៅមានកំរិត។ យុវជនជាច្រើននៅខ្វះចំណេះដឹងទាក់ទង់នឹងសុខភាពបន្តពូជដែលជាហេតុនាំឱ្យពួកគេមានផ្ទៃពោះដោយចៃដន្យ ការឆ្លងនូវកាមរោគ អត្រាប្រើប្រាស់ស្រោមអនាម័យទាប [1] និងអត្រាចាប់រំលោភលើក្មេងស្រីមានការកើនឡើង [2]។ សេវាបង្ការក្រោយប្រព្រឹត្តប្រឈមមិនទាន់មានភាពទូលំទូលាយទូលាយសម្រាប់មនុស្សទូទៅនៅឡើយ។ អ្វីដែលសំខាន់ជាងនេះទៅទៀតគឺ ធនធានសម្រាប់អនុវត្តកម្មវិធីបង្ការនូវមានការខ្វះខាតនៅឡើយ។

**ការម៉ាក់ងាយរើសអើង** បើតាមការសិក្សានាពេលថ្មីៗនេះបានបង្ហាញអោយឃើញថាការរើសអើងពីសំណាក់អ្នកផ្តល់សេវា ពីសំណាក់សហគមន៍ អ្នកជំងឺអេដស៍មានការរើសអើងដោយខ្លួនឯង អ្នកជំងឺអេដស៍ខ្លះទៀតធ្លាប់ត្រូវបានគេរំលោភបំពានសិទ្ធិនិងត្រូវបានគេបដិសេដមិនលក់ធានារ៉ាប់រងសុខភាពជូន។ ក្រុមងាយរងគ្រោះ រួមមានក្រុមអ្នកស្រលាញ់ភេទដូចគ្នា ក្រុមអ្នកប្រើបំពានគ្រឿងញៀន និងក្រុមអ្នកធ្វើការនៅតំបន់សេវាកម្សាន្តសប្បាយទទួលរងនូវការមើលស្រាលពីសំណាក់សហគមន៍ កន្លែងបម្រើការងារ និងអតិថិជន។

**កម្មវិធីថែទាំ គាំទ្រ និងព្យាបាល** កម្មវិធីព្យាបាលអ្នកជំងឺអេដស៍នៅតាមបណ្តាមន្ទីរឃុំឃាំងមានកម្រិតតិចតួចនៅឡើយ អត្រាគ្របដណ្តប់នៃឱសថប្រឆាំងមេរោគអេដស៍មានរហូត ៩២%[3] តែឱសថប្រឆាំងនឹងជំងឺឱកាសនិយមនៅមានការខ្វះខាត ការពិនិត្យឈាមរកជំងឺផ្សេ

---

[1] MARYP Survey, 2010, KHANA

[2] របាយការណ៍របស់អង្គការ ADHOC, LICADHO

[3] NCHADS

ងៗតម្រូវឱ្យបង់ប្រាក់ជាដើម។ អ្នកជំងឺអេដស៍ភាគច្រើនមិនទាន់ទទួលបានប័ណ្ណមូលនិធិសមធម៌ និងធនធានសម្រាប់បញ្ជូនអ្នកជំងឺទៅទទួលសេវាមានការថយចុះជាលំដាប់។ជាងនេះទៅទៀតការផ្តល់សេវាពីការផ្តល់ឥណទាននិងការផ្តល់មុខរបរដល់អ្នកទាំងនោះក៏មិនទាន់បានទូលំទូលាយនៅឡើយសំរាប់អ្នករងផលប៉ះពាល់ជាពិសេសកុមារកំព្រានិងកុមារដែលងាយរងគ្រោះ។ជាងនេះទៅទៀតនោះយើងក៏ត្រូវពិនិត្យមើលផងដែរនូវការបង្កើតច្បាប់និងគោលនយោបាយ ដើម្បីធានាថាច្បាប់និងគោលនយោបាយទាំងនោះមិនជាឧបសគ្គរាំងទៅដល់ការអនុវត្តនិការអប់រំផ្សព្វផ្សាយនិងការថែទាំព្យាបាលទៅដល់អ្នកដែលកំពុងត្រូវការសេវាទាំងនោះ។

លោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរព!

ដើម្បីធានាពីនិរន្តភាពសង្គមស៊ីវិលស្នើសុំទៅរាជរដ្ឋាភិបាល មេត្តាបង្កើននូវការប្តេជ្ញាចិត្តនិងការចូលរួមអោយបានខ្លាំងខ្លាបន្ថែមទៀតជាពិសេសការចូលរួមវិភាគទានផ្នែកថវិការបស់រដ្ឋាភិបាលអោយបានច្រើនថែមទៀតក្នុងការងារអេដស៍។ ដៃគូរអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធដទៃទៀត សូមបង្កើននូវធនធានហិរញ្ញវត្ថុ និងដោះនូវរបាំងនានា ដែលជាកត្តារាំងស្ទះដល់ដំណើរការអនុវត្តការងារប្រយុទ្ធនឹងជំងឺអេដស៍ និងការព្យាបាលជំងឺអេដស៍។

តាងនាមសង្គមសីវិលយើងខ្ញុំសូមលោកជំទាវ ឯកឧត្តម លោក លោកស្រី មេត្តាបង្កើននូវការប្តេជ្ញាចិត្តឱ្យបានខ្លាំងក្លាថែមទៀតទាំងផ្នែកបច្ចេកទេស និងគោលនយោបាយ។ ដូចដែលលោក ម៉ៃឃីល សាយឌីបេ ប្រធាន UNAIDS មានប្រសាសន៍ក្នុងវេទិកាសហគមន៍ នៅ ICAAP 10 ថា ភាពជាអ្នកដឹកនាំ និងសកម្មជនជនអេដស៍ជាចលករបង្កើតនូវធនធាន។

គណៈកម្មាធិការសំរបសំរួលប្រយុទ្ធនឹងជំងឺអេដស៍នឹងបន្តការសហការណ៍ជាមួយនឹងរាជរដ្ឋាភិបាលទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិក្នុងការសំរបសំរួលជាមួយនឹងអង្គការសង្គមសីវិលធ្វើយ៉ាងណាដើម្បីគៀងគរប្រភពធនធានពីប្រភពផ្សេងៗ បន្តជួយនូវការពង្រឹងយន្តការដែលមានស្រប់និងជួយផ្តល់ជាការចែករំលែកពត៌មានជាយុទ្ធសាស្រនានាដើម្បីធានាថាការអនុវត្តសកម្មភាពគឺស្របទៅនឹងផែនការថ្នាក់ជាតិ អ្វីដែលជាតំរូវការជាក់ស្តែងនៅតាមសហគមន៍និងការប្រើប្រាស់ថវិកាអោយមានប្រសិទ្ធភាពខ្ពស់ក្នុងការចូលរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលដើម្បីកាត់បន្ថយការរីករាលដាលនៃមេរោគអេដស៍និងផលប៉ះពាល់របស់វានៅក្នុងប្រទេសកម្ពុជា។

ទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ជួបប្រទះនឹងពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!